នេះហើយ គឺជាគោលបំណង នៃដំណើរ ក្នុងការដាស់ស្មារតីរបស់ព្រះក្រឹស្ណា ( Krishna consciousness )នៃលោកទាំងមូល ដែលកែសម្រួលយ៉ាងហ្មត់ចត់នៃសង្គមមនុស្សយើងនេះ។

យើងមិនបានបង្កើតវត្ថុទាំងឡាយណាដែលកកស្ទះនោះទេ។

ជាការពិតណាស់ទាំងនេះជាវិទ្យាសាស្ត្រ។

ប្រសិនបើអ្នកចង់បំពេញបេសកកម្មជីវិតរបស់អ្នក នោះអ្នកគួរតែទទួលយកដំបូន្មានរបស់ ព្រះគម្ពីរ " ភគវត ហ្គីតា" ដែលមានលក្ខណៈវិទ្យាសាស្ត្រ និង ជាទូន្មានដោយព្រះដែលជាបុគ្គលខ្ពង់ខ្ពស់បំផុត ដោយគ្មានខ្វះចន្លោះបន្តិចណាឡើយ។






( ដកស្រង់ពីការបង្រៀន ព្រះគម្ពីរ ភគវត នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៤ ក្នុងក្រុង មុំបៃ
Bhagavad-gita lecture, April 2, 1974, Bombay )



# វាគឺជាប្រព័ន្ធ



ផលិតនូវអ្វីដែលយើងត្រូវការ !

ហូបតែអ្វីដែលយើងបានផលិតមក !

នេះគឺជាច្បាប់ដែលបានចែងក្នុងគម្ពីរវេទ  អំពីការផលិតអាហារ និងការទទួលទានអាហារ។

ប្រសិនបើការប្រតិបត្តិបែបនេះត្រូវបានលើកយកមកណែនាំឡើងវិញ នោះពិភពលោកទាំងមូលនឹងមានការផ្លាស់ប្តូរទៅរកភាពប្រសើរ ជាពិសេសនោះគឺ ការអនុវត្តអោយបានខ្ជាប់ខ្ជួននូវរាល់រាត្រី។



មនុស្សជាច្រើន រួមបញ្ចូលទាំងសាវ: យើងផងដែរ បានកំពុងនិងទទួលទាននូវអាហារដែលគ្មានប្រភពច្បាស់លាស់ ជាអាហារដែលផ្ទុកទៅដោយសារធាតុគីមី និងថ្នាំសម្លាប់សត្វល្អិតដ៏ច្រើនលើសលប់ ពោលជាប្រភេទអាហារដែលគ្មានសារធាតុចិញ្ចឹមដែលបានពីធម្មជាតិដោយផ្ទាល់នោះទេ ទាំងនេះ គឺជាដើមចមដែលនាំអោយមានបញ្ហាសុខភាជាអន្តរាយរាបមិនអស់។

ដូច្នេះហើយទើបនាំឲ្យប្រព័ន្ធភាពស៊ាំនៃសារពាង្គកាយមនុស្សយើងថយចុះ ជាហេតុនាំឲ្យរាង្គកាយងាយ រងនូវរាល់ជម្ងឺគ្រប់ប្រភេទ ក្នុងនោះក៏រួមបញ្ចូលទាំងជំងឺកូវីដ ១៩ ផងដែរ។

គ្រប់ មជ្ឍមណ្ឌល អ៊ីស្កុន (ISKCON) និង រាល់គម្រោងការទាំងអស់ គួរចាត់ទុកការហូបចុក ជារឿងដ៏សំខាន់បំផុត ជាពិសេសក្នុងខណៈពេលដែលពិភពលោកកំពុងប្រឈមមុខទៅនិងការរីករាលដាលនៃជំងឺ។

យ៉ាងណាមិញ ទោះបីមានការរីករាលដាល ឬ មិនរីករាលដាលក៏ដោយក្តី ការគ្រប់គ្រងលើការហូបចុកគួរតែស្ថិតក្រោមស្តង់ដាមួយ ជានិច្ច។




គ្មានព្រះវិហារណាមួយ គួរតែលះបង់ចោលនូវការផលិតអាហារបែបធម្មជាតិសម្រាប់ឧទិសដល់ ទេពតា សាវ:សាធុកា និង សមាជិកក្រុមជំនុំរបស់ពួកគេឡើយ។

ដើម្បីអោយការប្រតិបត្តិទាំងនោះកើតឡើងទៅបាន ពួកយើងត្រូវចាប់ផ្តើមធ្វើការផ្លាស់ប្តូរជាគំរូ ដោយមើលអោយជាក់ និង យល់អោយច្បាស់ រវាងទំនាក់ទំនងនៃទស្សនៈវិជ្ជា និង របៀបរស់នៅរបស់យើងផ្ទាល់ជាមុនសិន។

របៀបរស់នៅ គឺសំដៅទៅលើ ថាតើយើងរស់នៅដោយរបៀបណា តើយើងរស់នៅទីណា តើយើងហូបអ្វី តើយើងធ្វើការងារអ្វី ទាំនេះត្រូវតែមានអត្ថន័យយ៉ាងពេញលេញដែលអាចឆ្លុះបញ្ចាំង ពីទស្សនៈរបស់យើងបាន។

ហើយទស្សនៈវិជ្ជានៃគម្ពីរវេទ គឺគ្តោបបញ្ចូល ទាំងវិមាត្រ អត្ថរូប និង វិញ្ញាណ នៃជីវិតដែលរក្សាអោយបាននូវអ្វីដែលជាផ្តត់គំនិតមូលដ្ឋាន និងគោលការណ៍នៃគម្ពីរ។



មានតែសាវ:ដែលបានលះបង់ និងជាបុគ្គល់ប្រកបដោយ ការយល់ដឹងផ្នែក វិទ្យាសាស្រ្តសម្ភារ:និយម និង វិញ្ញាណ ( ពួកត្រូវគេស្គាល់ថា Catur Vidya ) ដែលអាចនាំមកនូវការផ្លាស់ប្តូរក្នុងសង្គមនេះបាន។

ដូច្នេះហើយតម្រូវការចាំបាច់បំផុតនោះគឺ ធ្វើការណែនាំឡើងវិញនូវ វគ្គបណ្តុះបណ្តាល និង ការអប់រំបែបប្រពៃណីដូចជា ហ្គូរូកូឡាស់( Tranditonanl Gurukulas ) វិទ្យាស្ថាន វ៉ាណាស្រាម៉ា ( Varnasrama College )ដើម្បីជួយបង្កើតឡើងវិញ នូវរបៀបរស់បែបកសិកម្មរបស់ប្រជាជនវណ្ណៈកណ្តាល( វៃស្យ )។



ទាំងអស់នេះហើយដែលហៅថា ប្រព័ន្ធ ហើយវា ជានិច្ចកាលជាប្រព័ន្ធនៃសង្គម!នេះគឺជាអត្ថន័យនៃ ព្រះធម៌ សនតាណា ( Sanatana Dharma )៕ប្រសិនបើអ្នកចង់កែតម្រូវជីវិតរបស់អ្នក។ តើនរណាកំពុងផលិត គ្រាប់ធញ្ញជាតិជាអាហារ?

ពួកគេត្រូវបានស្គាល់ថា វៃស្យ ( Vaisyas )។ តើវៃស្យ ( Vaisyas ) ជាអ្វី? ប្រសិនបើគ្មានប្រពៃណីព្រាហ្មណ៍( brahminical culture )ទេ មនុស្សទាំងអស់គឺគ្មានបញ្ញា។ ប្រសិនបើគ្មានក្សត្រ ( ksatriya ) ទេ តើនរណានឹងផ្តល់ការការពារដល់អ្នក។ វាពិតជាមានភាពខ្វះចន្លោះច្រើនណាស់។ ទាំងនេះប្រសិនបើអ្នក ចង់កែប្រែនូវជីវិតអ្នក ព្រមទាំងសង្គមទាំងមូល មិនថាថ្នាក់ជាតិ ឬ អន្តរជាតិ ។ ដោយអ្វីៗដែលបាននិយាយមកនេះត្រូវបានចាត់ទុកជាអន្តរជាតិ នោះអ្នកត្រូវតែទទូលយកការទូន្មាន របស់ព្រះក្រឹស្នា ( Krishna. )

ការអនុវត្តន៍នេះ គឺត្រលប់ទៅទស្សនៈវិជ្ជានៃលោកអំពីជីវិតដែលនឹងដល់ទីបញ្ចប់។ មនុស្សលោក ត្រូវតែត្រលប់ទៅរករបៀបរស់នៅបែបកសិកម្ម ដែលមាន គោ ដី និង ការដាំដុះ ជាចំណេះដឹងដ៏សំខាន់ ដែលវាជាមូលដ្ឋាននៃជីវិតយើងវិញ។

មានមនុស្សកាន់តែច្រើនឡើងនៅជុំវិញពិភពលោក បានកំពុងតែចាប់ផ្តើមសាទរ និង ប្រឹងប្រែងយ៉ាង ខ្លាំង ដើម្បីឆ្លើយតបទៅនឹង ផ្នត់គំនិត នៃ ភូមិ ជីវចំរុះជីវភាព (sustainable eco villages)។ ទោះជាយ៉ាងណាក៏ដោយ បើគ្មាន ទស្សនៈវិទ្យាជាមូលដ្ឋាននៃគម្ពី ព្រះភគវត (Bhagavad Gita) ទេ ការប្រឹងប្រែងទាំងឡាយរបស់ពួកគេនឹងមិនស្ថិតថេរយូរអង្វែងឡើយ។



ការលាតត្រដាងទាំងនោះ ជាការបង្រៀនជាគ្រឹះក្នុងព្រះគម្ពីភគវត(Bhagavad Gita)វាប្រៀបបាននិងដែនកំណត់នៃគន្លងធម៌ ពិតមួយថាខុស ឬ ត្រូវបើទោះបីបំណងរបស់គេគិតថាថ្លៃថ្នូរក៏ដោយ។

ពួកគាត់គឺជាអ្នកដែលបានប្រាសចាក នូវបែបបទនៃគម្ពី ឬ ការប្រព្រឹត្តដែលយោងទៅតាមការសម្រេច ចិត្ត ភ្លាមៗ របស់គាត់ដើម្បីសម្រេចបាននូវ ភាពល្អឥតខ្ចោះ ឬ សុភមង្គល ឬ ដើម្បីទិសដៅកំពូលក្នុងជីវិតគេ។ ដូច្នោះមានការប្រតិបត្តិ ដ៏តឹងរឹងដូចខាងក្រោមនេះ ៖ អ្នកដែលមានលទ្ធិប្រជាធិបតេយ្យ មិនដឹងអ្វីដែលត្រូវធ្វើ ឬអ្វីដែលមិនត្រូវធ្វើ មិនថាអនាម័យ ឬ មិនមានអាកប្បកិរិយាសមរម្យ ឬមិនមានភាពស្មោះត្រង់ គឺនិងត្រូវបានសំដែងចេញដោយពួកគេផ្ទាល់។គេបានពោលពាក្យថា ពិភពលោកយើងនេះ គឺមិនពិតដោយគ្មានមូលដ្ឋាន មិនបានគ្រប់គ្រងដោយ ព្រះជាម្ចាស់។ពួកគេក៏បានពោលទៀតថាការមានបំណងប្រាថ្នាក្នុងការរួមភេពគ្មានអ្វីក្រៅពីកាមតណ្ហា។ រាល់ការសន្និដ្ឋានទាំងឡាយដែលមានចិត្តជាបីសាច នៃអ្នកដែលវង្វេង អ្នកដែលគ្មានបញ្ញា អ្នកដែលមិនបានចូលរួមបង្កើតស្នាដៃ អ្នកដែលប្រកបការងារមិនទៀងត្រង់ ទាំងអស់នោះ គឺមានន័យថាពួកគេកំពុងបំផ្លាញលោកយើងនេះ។



វិមាត្រអត្ថរូបនៃជីវិតគឺសំដៅទៅដល់មជ្ឈមណ្ឌលរបស់លោកជីតា ភីស្មៈទេវ (Bhismadeva) ដែលមានធនធានពីរសំខាន់ ទីមួយគឺ គោ និង ទីពីរគឺ ដី ដែលរោគសាស្ត្រ និង ជារូបមន្តដ៏ល្អឥតខ្ចោះ សម្រាប់និរន្តរភាពសេដ្ឋកិច្ចពិតប្រាកដ ដែលផ្អែកទៅលើការធ្វើមូលដ្ឋានីយកម្ម និង ការរស់នៅយ៉ាងសាមញ្ញ។

(**មហាភារតៈអនុសាសាណា ប៉ាវ៉ា ជំពូក** 69 **ឈ្មោះ ដាណា ប៉ាវ៉ា ប៉ាវ៉ា**)
(Mahabharata, Anusasana Parva, Chapter 69, Dana Parva Parva)

ស៊ីឡា ប្រាប៊ូប៉ាដា ពន្យល់ថា៖




"ព្រះក្រឹស្នាព្រមទាំងមិត្តភក្តិទ្រង់ គឺជាក្មេងគង្វាលគោ ដោយទ្រង់និង មិត្តទ្រង់តែងតែទៅជាមួយគោ នៅឯវាលស្មៅពេញមួយថ្ងៃ។

នេះគឺជាប្រព័ន្ធ ពីព្រោះមនុស្សជំនាន់នោះ មានការពេញចិត្តចំពោះដី និងគោ។សកម្មភាពគឺមានតែប៉ុន្នឹងជាប្រចាំថ្ងៃ"។

(**ដកស្រង់ពីការបង្រៀន ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ១៩៦៨ នៅទីក្រុង សៀថល** Seatle, USA)

ចាប់តាំងពីពេលដែលបដិវត្តន៍ឧស្សាហកម្មមុន២០០ឆ្នាំមុនកន្លងទៅមេដឹកនាំដែលគ្មានទំនួលខុសត្រូវ ទាំងឡាយក្នុងលោកបានប្រមាថនូវអំណោយពីធម្មជាតិទាំងពីរនេះ ទាំងដែលវាជាធនធានដែរមានសារៈសំខាន់យ៉ាងពិតប្រាកដសម្រាប់ជីវិតយើង ហើយគេបែរជាបានរុញច្រានស្មារតីនៃមនុស្សជាតិទាំងអស់ឲ្យកើនឡើងនូវភាព ស្មុកស្មាញនិងភាពចលាចលដែលមិនអាចកែប្រែអោយល្អបានទៅវិញ ដោយ ទាំងនេះអាចជាហេតុផលនៃការវិនាសអន្តរាយនៃលោកទាំងមូលផងដែរ។

បច្ចុប្បន្នថ្វីបើនៅតែមាន រោចចក្រផលិត ផលិតផលពីទឹកដោះគោ និង កសិពាណិជ្ជកម្មក្តី តែពួកវាបានបំផ្លាញតុល្យភាពអេកូឡូស៊ីជាសាកលដែលធ្វើអោយមានការកើនឡើងនូវចំនួនមនុស្សជាច្រើន ដែលធ្លាក់ចូលក្នុងរបៀបរស់នៅបែបសិប្បនិម្មិត និង របៀបរស់នៅមិនល្អក្នុងទីក្រុងនោះ។

ទោះជាយ៉ាងណាក៏ដោយ មនុស្សគ្រប់រូបនឹងយល់ពី សារៈសំខាន់នៃជីវិតរបស់វិមាត្រអត្តរូបទាំងពីរ ដែលមានគោ និង ដី នេះ ដែលលោកតាភីស្មៈទេវ (Bhismadeva) ផ្តល់អោយជាមុនសិន ដោយមិនចាំបាច់ត្រូវតែយល់ពីវិមាត្រនៃវិញ្ញាណដែល ពោលជាចំណេះដឹងក៏បាន។គោលដៅនៃចំណេះដឹងដែលជាមូលដ្ឋាននៃជីវិតនោះគឺ ការយល់ច្បាស់ពីខ្លួនឯង ដែលជាចំណុចកំពូលនៃអភិញ្ញាណ របស់ព្រះក្រឹស្ណា។

ចំណេះដឹងនេះគឺត្រូវបានចែងជាពិសេសក្នុងសៀវភៅជំនួយបញ្ញាស៊ីជំរៅសាកលសម្រាប់មនុស្សគ្រប់រូបពិចារណាការបង្រៀនប្រៀនប្រដៅដែលមានអាយុកាលច្រើនឆ្នាំនៃព្រះគម្ពីភគវត ដែលបានបង្ហាញ ដោយព្រះគ្រូសំខាន់បំផុតនៃយើងក្នុងយុគ្គសម័យទំនើបនេះគឺ ព្រះគ្រូ ស៊្រីឡា ប្រាប៊ូប៉ាដា(Srila Prabhupada)។



ហើយនៅក្នុងសៀវភៅជំនួយបញ្ញា និងចំណេះដឹង យើងពិតជាបានរកឃើញ ឯកសារយោង និងតឹកតាំង អំពីការផលិតអាហារដោយខ្លួនឯងនេះ ព្រមរបៀបនៃការផលិតសមញ្ញ និង ថ្លៃថ្នូរបំផុត។ ជាថ្មីម្តងទៀតព្រះគ្រូ ស៊្រីឡា ប្រាប៊ូប៉ាដាថ (Srila Prabhupada) ជំរុញអោយយើងយល់ និង អនុវត្ត សេចក្តីណែនាំជាមូលដ្ឋានដែលបានរកឃើញក្នុងព្រះគម្ពី ដូចខខាងក្រោមនេះ៖

-អានណាត ប៊ាវ៉ាន់ទី ប៊ូតានី (annad bhavanti bhutani)



-ប៉ាវ៉ានចានយ៉ាត អានណា សាំប៊ាវ៉ាហា (parjanyad anna-sambhavah)

-យ៉ាណាត ប៊ាវ៉ាន់ទី ប៉ាចានយូ (yajnad bhavati parjanyo)

-យ៉ាណាហា កម្មា សាមូដប៊ាវ៉ាហា (yajnah karma-samudbhavah)

គ្រប់ភាវៈមានជីវិតទាំងអស់ចិញ្ចឹមជីវិតដោយ គ្រាប់ធញ្ញជាតិជាអាហារដែលផលិតដោយទឹកភ្លៀងហើយ ភ្លៀងគឺកើតឡើងដោយការបូជាយ៉ាញ់ហើយការបូជាយ៉ាញ់ទាំងឡាយកើតមកពីភារកិច្ចដែលបានកំណត់អោយ។ ភារកិច្ចដែលបានកំណត់អោយជាពិសេសទាំងអស់គឺសំដៅដល់ ការតព្វកិច្ច នៃគ្រួសារនីមួយៗ ដែលមានកាតព្វកិច្ចដាំដុះណោះឯង។ វាមិនគ្រាន់តែជាទ្រឹស្តីទេ ប៉ុន្តែវាជាការអនុវត្តន៍ជាក់ស្តែង។ ការសម្តែងដោយ ព្រះគ្រូ ស៊្រីឡា ប្រាប៊ូប៉ាដា។ គួរតែមានការកែ សម្រួលយ៉ាងហ្មត់ចត់ក្នុងប្រព័ន្ធនៃសង្គម ហើយសង្គមទាំងមូលគួរតែត្រលប់ទៅ គោលការណ៍នៃគម្ពីវេទ (Vedic Principles) ដែលមាន វណ្ណៈ និង អាសនៈ ធំទាំងបួន។ប្រសិនបើគ្រួសារនីមួយៗបានប្រកាន់ខ្ជាប់នូវការធ្វើកសិកម្ម ជាកាតព្វកិច្ចដែលត្រូវបានកំណត់អោយ ដូចដែលបានចែងក្នុងវប្បធម៌នៃគម្ពីវេទយើងនោះវាពិតជាសមហេតុផលណាស់ដែលក្មេងប្រុសភាគ ច្រើនគួរតែយកទៅធ្វើកសិកម្ម ដោយការធ្វើកសិកម្មគឺ ជាសកម្មភាពប្រៀបាននិងការបង្ហាញដោយផ្ទាល់របស់ព្រះក្រឹស្ណានៃយើង និង ក្មេងគង្វាលគោដែលជាមិត្តជាច្រើនរបស់ទ្រង់ក្នុង ភូមិ វ្រិនដាវ៉ាណា(Vrindavana)។ នេះនឹងលាត់ត្រដាងឲ្យឃើញច្បាស់ និង បញ្ចប់នូវ អារ្យធម៌ សត្តឃាតរបស់មនុស្ស សម័យទំនើប។ ភាពរីកចម្រើននៃអរិយធម៌ មានន័យថា ភាពរីកចម្រើននៃសត្តឃាត ភាពរីកចម្រើននៃអគារកប់ពពក ភាពរីកចម្រើននៃគ្រាប់បែកប្រល័យលោក ភាពរីកចម្រើននៃទស្សនៈវិទ្យា ហ្វ្រូដ (Freud Philosophy)។ ទាំងនេះគឺជាភាពរីកចម្រើន។ ប្រធានបទទាំងអស់ដែលបានរៀបរាបខាងដើមគឺដូចគ្នា គ្មាននរណាម្នាក់ទាមទារអោយមានការអប់រំលើប្រធានបទទាំងអស់នេះទេ។ ការអប់រំពិតប្រាកដ គឺវិធីដោះស្រាយ បញ្ហាជីវិត ដូចជា ភាពចាស់ កើត ស្លាប់ និង ថាតើត្រូវត្រលប់ទៅផ្ទះដោយរបៀបណា នោះទើបជាការអប់រំពិត។

(Room Conversation, July 11, 1973, London)
(ការសន្ទនាគ្នា នៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ១៩៧៣ ក្នុងទីក្រុងឡុង)